# សង្គមស៊ីវិលស្នើរដ្ឋសភាអនុម័តសេចក្តីព្រាងច្បាប់ចរាចរណ៍ផ្លូវគោកថ្មីឲ្យបានឆាប់

Posted about 1 year ago | Comments Off on សង្គមស៊ីវិលស្នើរដ្ឋសភាអនុម័តសេចក្តីព្រាងច្បាប់ចរាចរណ៍ផ្លូវគោកថ្មីឲ្យបានឆាប់

ដោយ ឡេង ម៉ាលី
2014-09-12
**RFA**

**ស្តាប់ ឬ ទាញយកសំឡេង**



*ម៉ូតូកង់ដែលទទួលរងការខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍ ត្រូវគេដឹកជញ្ជូនទៅស្នងការខេត្តកំពង់ចាម នៅថ្ងៃទី២៣ កុម្ភៈ ឆ្នាំ ២០១៤។ RFA/Saut Sokprathna*

គ្រោះថ្នាក់ចរាចរណ៍ នៅតែជាមូលហេតុធ្វើឱ្យមនុស្សស្លាប់នាំមុខមួយនៅប្រទេសកម្ពុជា។ អង្គការសង្គមស៊ីវិលដែលធ្វើការខាងសុវត្ថិភាពចរាចរណ៍ ស្វាគមន៍សេចក្តីព្រាងច្បាប់ចរាចរណ៍ផ្លូវគោកថ្មី ដែលរដ្ឋាភិបាលអនុម័ត និងទទូចសភាឱ្យចេញបានឆាប់ៗ។

សម្ព័ន្ធភាពអង្គការសង្គមស៊ីវិល និងវិស័យឯកជន ដែលធ្វើការខាងសុវត្ថិភាពចរាចរណ៍នៅកម្ពុជា មានសមាជិក ៩០ស្ថាប័ន ចង់ឱ្យសភាអនុម័តសេចក្តីព្រាងច្បាប់ចរាចរណ៍ផ្លូវគោកថ្មីឱ្យបានឆាប់ ដើម្បីសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋ និងទប់ស្កាត់គ្រោះមហន្តរាយនានា ដែលបង្កដោយគ្រោះថ្នាក់ចរាចរណ៍។

ថ្លែងក្នុងសិក្ខាសាលាស្តីពីសុវត្ថិភាពចរាចរណ៍ នៅថ្ងៃទី១០ កញ្ញា នាយកស្តីទីនៃវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ លោក ឡាំ សុជាតិ ថ្លែងថា អង្គការលោកគាំទ្រច្បាប់ចរាចរណ៍ថ្មីពេញទំហឹង ព្រោះសេចក្តីព្រាងច្បាប់ថ្មីនេះ ត្រូវបានពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល និងតួអង្គពាក់ព័ន្ធបានទូលំទូលាយ។ លោកបន្តថា ច្បាប់ថ្មីនឹងមានការកែលំអច្រើនជាងច្បាប់បច្ចុប្បន្ន៖ *«ជាពិសេស ការដាក់ទោសទណ្ឌបន្ថែមទៅលើអ្នកដែលល្មើសច្បាប់ចរាចរណ៍ ទាំងការផាកពិន័យ ទៅលើអ្នកល្មើសច្បាប់ចរាចរណ៍ ពីព្រោះថា ការល្មើសច្បាប់ចរាចរណ៍កន្លងមកនេះ បង្កឱ្យប្រជាជនកម្ពុជា ស្លាប់ច្រើនណាស់ មួយឆ្នាំជិត ២ពាន់នាក់ ដោយសារតែបញ្ហាមិនគោរពច្បាប់ចរាចរណ៍។ អ៊ីចឹង ច្បាប់ថ្មីនេះមិនមែនថាយើងគាំទ្រនូវការដាក់ទោសទណ្ឌឱ្យធ្ងន់ទៅលើប្រជាជនខ្មែរទូទៅទេ ប៉ុន្តែយើងគាំទ្រការដាក់ទោសទណ្ឌឱ្យធ្ងន់ទៅលើអ្នកល្មើសច្បាប់ចរាចរណ៍ ដែលបង្កដោយមានការរបួស ឬក៏ស្លាប់អាយុជីវិតមនុស្ស ដោយសារតែគាត់មិនគោរពច្បាប់ចរាចរណ៍»*។

ប្រធានគម្រោងយុវជនកាកបាទក្រហម និងសុវត្ថិភាពចរាចរណ៍ នៃកាកបាទក្រហមកម្ពុជា លោក ឌឹម សុផល មានប្រសាសន៍ថា




Deputy gov caught vicious beating of innocent bystander.
លោក សុខ ពេញវុធ អភិបាលរងខណ្ឌដូនពេញ បញ្ចេញអំពើហិង្សាយ៉ាង សាហាវ វាយអ្នករត់ ម៉ូតូឌុប ដែលគ្រាន់តែអង្គុយក្បែរ

## POLITICAL UNREST OF JANUARY

The slaughter of innocent people continues in Cambodia.

Jan. 28 - Strike on Road #3 - For more info, go to https://www.facebook.com/camnews.org

Violence crackdown - Jan. 27 - In front of Ministry of Information - Phnom Penh
Violence Act by Sok Penh Vuth
Violence Act by Phnom Penh Authority
Act of Human Rights Violation

Violence crackdown - Jan. 26 - Freedom Park - Phnom Penh Blood-shed at Freedom Park
Freedom Park?

This is the photo to be witnessed about those animals of Hun Sen acted the cheapest and cruelly as Kem Sokha said when he made a press conference on Jan 26,2014 after returning from Kampong Chham.
To be witnessed

Forcefully arrested and detained - Jan. 21. In front of French Embassy, U.S. Embassy, & UK Embassy
Activists Forcefully Arrested

Jan. 19 - in front of Royal Palace - Phnom Penh
A small crowd gathers for the release of 23 activists & workers arrested this month.
Two Arrested

January 2,3,4, 2014 - Workers & Political Activists under Attack: 2014 Opens to a Sustained Campaign of Violence and Arrests on Veng Sreng, Economic Zone of Phnom Penh. At least 6 savagely killed, 44 seriously injured, and

សេចក្ដីព្រាងច្បាប់ចរាចរណ៍ផ្លូវគោកថ្មី ត្រូវបានកែលំអចេញពីច្បាប់ចាស់ជាង ៤០%។ មានចំណុចសំខាន់ៗមួយចំនួន ដែលត្រូវបានកែលំអខ្លឹមសាររឹតតែច្បាស់ មានជាអាទិ៍ គឺខ្លឹមសារទាក់ទងនឹងការរឹតបន្តឹងលើការពាក់មួកសុវត្ថិភាព ការបើកបរក្រោមឥទ្ធិពលស្រវឹង ខ្សែក្រវាត់សុវត្ថិភាព កៅអីសុវត្ថិភាពសម្រាប់កុមារ ប័ណ្ណបើកបរ រចនាសម្ព័ន្ធគណៈកម្មការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ការឃាត់យានយន្ត និងការបង្កើនការផាកពិន័យ និងកម្រិតទោស។ លោក ឌឹម សុផល ថ្លែងថា គ្រោះថ្នាក់ចរាចរណ៍ធ្វើឱ្យកម្ពុជាខាតបង់ច្រើនក្នុងមួយឆ្នាំៗ៖ *«ក្នុងមួយឆ្នាំ គឺយើងបាត់បង់ជីវិតមនុស្សស្ទើរតែ ២ពាន់នាក់ហើយ ជាពិសេសនៅក្នុងឆ្នាំ២០១៣ កន្លងមកនេះ យើងបាត់បង់ជីវិតមនុស្សរហូតដល់ ១.៩៥០នាក់ ហើយឆ្នាំកន្លងៗមកហ្នឹង សុទ្ធអត្រាកើនឡើងជិត ២ពាន់នាក់ ហើយមានអ្នករបួសធ្ងន់ស្រាល គឺឡើងរហូតដល់ ១ម៉ឺន ៥ពាន់នាក់។ យើងខាតបង់ច្រើន។ អ៊ីចឹងបើសិនជាដល់ឆ្នាំ២០២០ បើសិនជាយើងចូលរួមសហការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្មីនេះ គឺយើងអាចសន្សំថវិការហូតដល់ ១.២៣០លានដុល្លារ»*។

លោកបង្ហាញថា ប្រសិនបើគ្មានច្បាប់ចរាចរណ៍ផ្លូវគោកពេញលេញមួយ ដើម្បីអនុវត្តទេ នឹងមានមនុស្សយ៉ាងតិច ៣ពាន់ ២រយនាក់ស្លាប់ជារៀងរាល់ឆ្នាំ។

មន្ត្រីកម្មវិធីដៃគូសុវត្ថិភាពចរាចរណ៍សកល ដែលភាសាអង់គ្លេសហៅថា (Global Road Safety Partnership) ប្រចាំនៅកម្ពុជា លោក គង់ សុវណ្ណ សង្ឃឹមថា ច្បាប់ចរាចរណ៍ថ្មីនឹងផ្ដល់ផលប្រយោជន៍ធំធេងដល់ពលរដ្ឋកម្ពុជា ឱ្យចៀសផុតពីគ្រោះថ្នាក់ចរាចរណ៍។ លោកថា នៅពេលមានច្បាប់ចរាចរណ៍មួយពេញលេញ ហើយអនុវត្តស្របតាមផែនការសកម្មភាព និងគោលនយោបាយថ្នាក់ជាតិដល់ឆ្នាំ២០២០ កម្ពុជា នឹងអាចកាត់បន្ថយអត្រាស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ពាក់កណ្ដាល៖ *«ដូច្នេះការអនុវត្តជោគជ័យជាមួយច្បាប់ និងច្បាប់ចរាចរណ៍ និងសកម្មភាពគោលធំៗនេះ នឹងធ្វើកម្ពុជា ត្រឹមឆ្នាំ២០២០ អាចជួយសង្គ្រោះជីវិតមនុស្សបាន ៧.៣៥០នាក់ និងជួយសន្សំថវិកាពីខាតបង់ពីគ្រោះថ្នាក់ចរាចរណ៍បានរហូតទៅដល់ ១លាន ២៣០លានដុល្លារ និងជួយកុំឱ្យមានជនរងគ្រោះរបួសក្បាលបាន ១០.៥៧២នាក់។ នេះគោល ៥០%»*។

តួលេខថ្នាក់ជាតិនៅឆ្នាំ២០១៣ បង្ហាញថា គ្រោះថ្នាក់ចរាចរណ៍នៅប្រទេសកម្ពុជា ខាតថវិកាចំនួន ១ ម៉ឺន ៥ពាន់លានដុល្លារ សម្លាប់មនុស្សជិត ២ពាន់នាក់ និងរបួសពិការ ១ម៉ឺន ៥ពាន់នាក់ ដែលភាគច្រើនជាក្រុមមនុស្សមានអាយុពី ១៥ ទៅ ៤៤ឆ្នាំ ជាកសិករ និងកម្មករ។ ជនរងគ្រោះ ៧០% ជាអ្នកប្រើប្រាស់ម៉ូតូ បានស្លាប់ដោយសាររបួសក្បាល ដែលភាគច្រើនមិនបានប្រើប្រាស់មួកសុវត្ថិភាព។ ជនរងគ្រោះជាអ្នកប្រើប្រាស់ម៉ូតូ ៦៧% ស្លាប់ដោយសារបើកលើសល្បឿនច្បាប់កំណត់។

ច្បាប់ចរាចរណ៍ចាស់ ត្រូវបានអ្នកធ្វើការខាងសុវត្ថិភាពចរាចរណ៍ជាតិ និងអន្តរជាតិ វាយតម្លៃថាមានលក្ខណៈមិនស្របតាមស្ថានភាពជាក់ស្ដែង ហើយការផាកពិន័យ និងការដាក់ទោសនៅមានកម្រិតទាប និងការពង្រឹងការអនុវត្តច្បាប់នៅខ្សោយ។ ដូច្នេះកម្ពុជា ត្រូវការកែលំអច្បាប់នេះ ឱ្យឆ្លើយតបនឹងបញ្ហាគ្រោះថ្នាក់ចរាចរណ៍ដែលកំពុងកើតឡើងធ្ងន់ធ្ងរ៕

**កំណត់ចំណាំចំពោះអ្នកបញ្ចូលមតិនៅក្នុងអត្ថបទនេះ៖ *ដើម្បីរក្សាសេចក្ដីថ្លៃថ្នូរ យើងខ្ញុំនឹងផ្សាយតែមតិណា ដែលមិនជេរប្រមាថដល់អ្នកដទៃប៉ុណ្ណោះ។***

---

### អត្ថបទដែលទាក់ទង


- គ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជានៅតែមានតួលេខខ្ពស់គួរឲ្យព្រួយបារម្ភ
- តុលាការខេត្តកំពង់ឆ្នាំងលើកពេលប្រកាសសាលក្រមអ្នកកាសែត៦នាក់
- តុលាការភ្នំពេញកោះហៅព្រះភិក្ខុ លួន សុវ៉ាត ចូលបំភ្លឺពីបទសង្ស័យក្បត់ជាតិ
- យុវជន៣នាក់របស់បក្សសង្គ្រោះជាតិត្រូវតុលាការកោះហៅឲ្យចូលបំភ្លឺជាថ្មី
- ក្លឹបអ្នកកាសែតអំពាវនាវដល់តុលាការខេត្តកំពង់ឆ្នាំងផ្ដល់យុត្តិធម៌ដល់អ្នកកាសែត៦នាក់
- កម្ពុជាត្រៀមមេធាវីតតាំងជាមួយតុលាការថៃរកយុត្តិធម៌ឲ្យពលរដ្ឋខ្មែរ៣៣នាក់
- ការឆបោកនៃការបណ្ដាក់ទុនរួមគ្នាបង្កើតក្រុមហ៊ុននឹងប៉ះពាល់ដល់ការនាំចេញអង្ករ
- ព្រះរាជអាជ្ញារងបញ្ជូនសំណុំរឿងជនជាតិវៀតណាមកាប់យុវជនខ្មែរទៅចៅក្រមស៊ើបសួរ
- សាលារាជធានីផ្ដល់សេវាពិសេសសម្រាប់អតិថិជនជិះឡានក្រុង


### Recent Articles


- គណបក្សថ្មីមួយថ្កោលទោសអំពើហិង្សាលើអ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ
- បទយកការណ៍៖ ពលរដ្ឋខកចិត្តនឹងរដ្ឋាភិបាលដែលមិនបានទប់ស្កាត់ការប្រើហិង្សាលើតំណាងរាស្ត្រ
- កងទ័ពចូលរួមអំពាវនាវឲ្យលោក កឹម សុខា ចុះចេញពីតំណែងជាអនុប្រធានរដ្ឋសភា
- មន្ត្រីបដិសេធការចោទប្រកាន់ពីបទបរិហារកេរ្ដិ៍ទាក់ទិនការបង្ហោះសារតាមហ្វេសប៊ុក
- ពលរដ្ឋបារម្ភព្រោះអាជ្ញាធរគ្មានឆន្ទៈការពារសុវត្ថិភាពក្នុងករណីអំពើហិង្សាលើតំណាងរាស្ត្រ
- លោក កឹម សុខា ដឹកនាំមន្ត្រីគណបក្សទៅថៃសួរសុខទុក្ខ


### What Next?


- Retweet this post on Twitter
- Like this post on Facebook
- StumbleUpon this post
- Digg this post
- Bookmark on del.icio.us


23 arrested and detained for a month now.
Violence Clash of Veng Sreng

"Hun Sen's government violates human rights on a daily basis by violently preventing the opposition, trade unions, activists and others from gathering to demand political change. Countries at the Human Rights Council should condemn this brutal crackdown and insist the Cambodian government engage in serious reforms." ....Juliette de Rivero, Geneva director
Read more...


AdChoices


តំណាងរាស្ត្ររងរបួស

- បទសម្ភាសន៍ជាមួយលោក គង់ សភា និងលោក ញ៉យ ចំរើន តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិដែលរងរបួស
- សង្គមស៊ីវិលថ្កោលទោសហិង្សាលើតំណាងរាស្ត្រគណបក្សជំទាស់
- សង្គមស៊ីវិលស្នើឲ្យមានការស៊ើបអង្កេតករណីទាហានដាក់ញត្តិទាមទារដកលោក កឹម សុខា
- សាក្សីឃើញពួកខ្មែរក្រហមជ្រើសរើសជនជាតិវៀតណាមយកទៅសម្លាប់
- រដ្ឋាភិបាលសោកស្តាយនិងថ្កោលទោសការវាយប្រហារមកលើតំណាងរាស្ត្រសង្គ្រោះជាតិ
- ពលរដ្ឋចូលរួមក្នុងពិធីបុណ្យនៅខេត្តបាត់ដំបងច្រើនជាងឆ្នាំមុន (វីដេអូ)
- សហភាពអឺរ៉ុបប្រចាំកម្ពុជាអំពាវនាវឲ្យអាជ្ញាធរកម្ពុជារកមុខរកជនដែលវាយប្រហារតំណាងរាស្ត្រ
- ការប្រើហិង្សាលើតំណាងរាស្ត្រគណបក្សប្រឆាំង (វីដេអូ)
- Human Rights Watch អំពាវនាវឱ្យប្រទេសម្ចាស់ជំនួយប្រាប់គណបក្សកាន់អំណាចបញ្ឈប់ការប្រើហិង្សា
- HRW ជំរុញឲ្យ អ.ស.ប និងប្រទេសម្ចាស់ជំនួយ មានវិធានការលើករណីវាយដំតំណាងរាស្ត្រ
- លោក សម រង្ស៊ី ថាលោក ហ៊ុន សែន ចង់រកលេសបង្កើតព្រឹត្តិការណ៍ពន្យារការបោះឆ្នោត
- អង្គការអន្តរជាតិរកឃើញថាក្រុមហ៊ុនវៀតណាមរំលោភសិទ្ធិមនុស្សនិងកាប់បំផ្លាញព្រៃឈើ
- កម្ពុជា-បារាំង ចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចីសម្បទានតម្លៃប្រមាណ១១៥លានដុល្លារ
- អាងស្តុកទឹកមួយក្នុងខណ្ឌដង្កោហៀរលិចផ្ទះពលរដ្ឋនៅក្បែរនោះ (វីដេអូ)



© 2015 Cambodia News | Khmer News – ព័ត៌មានខ្មែរ . All rights reserved. · Entries RSS · Comments RSS

Powered by Cambodian Information Center